# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ៖ ១១៣ ត១.ក្រ១១

ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣៣៩៦

ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨

-សំណុំរឿងស៊ើបសួរលេខ៖ ១៩២៣

ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨

-សំណុំរឿងជំនុំជម្រះលេខ៖ ៣៩២១

ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨

## នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង១៤និង ៣០នាទីរសៀល និងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង០៨និង ៣០នាទីព្រឹក នៅសាលសវនាការទី ៣ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:៣៣៩៦ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ សាសនាព្រះពុទ្ធ មុខរបរធ្វើចំការ ទីកន្លែងកំណើតនៅឃុំយ៉ាងថូន ស្រុកណងមួន ខេត្តលុបបូរី ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៥៣ ក្រុមទី ៣ តំបន់យ៉ាងថូន ស្រុកណងមួង ខេត្តលុបបូរី ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) មានប្តីឈ្មោះ [redacted] មានកូនចំនួន០៣នាក់ ជាទីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៤៥២១ "ជ១"ដ.ឃ.ជ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨។

២. ឈ្មោះ [redacted] RUTHAIRAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើតនៅឃុំយ៉ាងថូន ស្រុកណងមួន ខេត្តលុបបូរី ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៨៥/៣៥ ឃុំឡាហេង ស្រុកឡាលំកែវ ខេត្តប្រាធុមថានី ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) មានប្តីឈ្មោះ [redacted] មានកូនចំនួន០១នាក់ ជាទីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៤៥២០ "ជ១" ដ.ឃ.ជ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨។

៣. ឈ្មោះ [redacted] KANOKNUD ហៅ ភាន ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិថៃ មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅNO 307 Soi On-nuch Sub-District ទីក្រុង Bangkok ប្រទេសថៃ កាន់អត្តសញ្ញាណប័ណ្ណលេខ 3480500578193 កាន់លិខិតឆ្លងដែនលេខ AA8158339 ជាទីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

ជាប់ចោទពីបទៈ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** (ពីប្រទេសកម្ពុជាទៅកាន់ទីក្រុងតូក្យូ ប្រទេសជប៉ុន) ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃ០៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោកមេធា[redacted] **ហួឡាយ** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WORAPHA និង ឈ្មោះ SORNSIN RUTHAIRAT។

-លោកមេធាវី [redacted] **ណូវ៉ា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហៅ ក្វាង។

## អង្គហេតុនៃរឿងមានដូចតទៅ:

-កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង២៣ និង៥០នាទី មន្ត្រីនគរបាលនៃមន្ទីរប្រឆាំងគ្រឿងញៀន និងដោយសហការជាមួយសមត្ថកិច្ចគយ និងរដ្ឋាករ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានធ្វើការឃាត់ខ្លួនជនត្រូវចោទជាអ្នកដំណើរចំនួន០២នាក់ មានឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ ៤២ឆ្នាំ ជនជាតិថៃ កាន់លិខិតឆ្លងដែនលេខ AA ៨៥៧៩៨៩៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ និងឈ្មោះ [redacted] RUTHAIRAT ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិថៃ កាន់លិខិតឆ្លងដែនលេខ AA៨៧៣៩៩០៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ នៅចំណុចស្ថានីយ៍អ្នកចេញដំណើរ ពីប្រទេសកម្ពុជាទៅកាន់ទីក្រុងតូក្យូ ប្រទេសជប៉ុន តាមជើងហោះហើរលេខ NH៨១៨ និងបានឆែកឆេរក្នុងអាវរងាររបស់ជនត្រូវចោទទាំង ០២នាក់ រកឃើញមានម្សៅក្រាមពណ៌ស ប្រភេទមេតំហ្វេតាមីន ដែលលាក់បង្កប់ក្នុងអាវរងាររបស់ជនត្រូវចោទឈ្មោះ [redacted] RUTHAIRAT មានទម្ងន់សរុប ២ ៧៥៦,៤៤ក្រាម និងរបស់ជនត្រូវចោទឈ្មោះ [redacted] WORAPHA មានទម្ងន់សរុប ១ ៧៥០,៧៦ ក្រាម។ ចំណែកឈ្មោះ ក្វាង ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ជនជាតិថៃ ប្រើប្រាស់ទូរស័ព្ទលេខ ០៦៩ [redacted] និងលេខ [redacted] ដែលជាម្ចាស់គ្រឿងញៀន និងជាមេក្លោង ជាអ្នករៀបចំចាត់ចែង និងប្រគល់សារធាតុញៀនឱ្យជនត្រូវចោទទាំង០២នាក់ នេះនៅខេត្តសៀមរាបនោះ បានគេចខ្លួនបាត់។

-បានឃើញ របាយការណ៍បញ្ជូនលេខ: ៨៤៧ រ.ប.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ របស់មន្ទីរប្រឆាំងគ្រឿងញៀន។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១៩៥៩ អ.យ.ប ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៣៦១២ អ.យ.ប ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៥៥៣៣ "ជ១"ង.ដ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] WORAPHA បានឆ្លើយនាពេលសវនាការថា ៖ ខ្លួនធ្លាប់មកកម្ពុជាចំនួន០៣លើក រួចមកហើយរួមទាំងលើកនេះ។ ដោយមុនដំបូងខ្លួនបានស្គាល់មិត្តភ័ក្តម្នាក់ តែពុំស្គាល់ឈ្មោះ ពិតទេ គឺស្គាល់តែឈ្មោះហៅក្រៅ គឺឈ្មោះ ក្វាង ភេទស្រី ជនជាតិថៃ គឺស្គាល់តាំងពីម្ភៃឆ្នាំមុនមកម្លេះ ដោយពេលនោះខ្លួនបានធ្វើកម្មកររោងចក្រ



Scanned with CamScanner

ក្រដាសរយៈពេល១០ឆ្នាំ ក៏បានត្រលប់ទៅស្រុកកំណើតវិញ ហើយចាប់ពីពេលនោះមករវាងខ្លួននិងឈ្មោះ ក្វាង ពុំសូវបានទាក់ទងគ្នាទេ។ លើកទី០១ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ខ្លួនបានជិះយន្តហោះមកពីប្រទេសថៃ ឆ្ពោះមករាជធានីភ្នំពេញ ហើយបានស្នាក់នៅសណ្ឋាគាររយៈពេល០៣ថ្ងៃ ក៏បានជិះតាក់ស៊ីទៅប៉ោយប៉ែត ដើម្បីទៅលេងបងថ្លៃស្រីបន្ទាប់មកក៏បានត្រលប់មកភ្នំពេញវិញ ជាមួយបងថ្លៃស្រី រួមទាំងមិត្តភក្តិរបស់គាត់ ភេទស្រីចំនួន០៣នាក់ផងដែរ ពេលមកដល់ភ្នំពេញ ពួកខ្លួនពុំបានស្នាក់នៅទីណាទេ គឺធ្វើដំណើរឆ្ពោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ បន្តដំណើរទៅប្រទេសជប៉ុន ហើយបានស្នាក់នៅទីនោះរយៈពេលចំនួន០២ថ្ងៃទើបត្រលប់មកថៃវិញ។ លើកទី០២នៅថ្ងៃមិនចាំ ខែកញ្ញា ឆ្នាំ២០១៧ ឈ្មោះ ក្វាង បានទូរស័ព្ទមកខ្លួនហើយបានប្រាប់ខ្លួនឱ្យនាំប្អូនថ្លៃរបស់ខ្លួនឈ្មោះ [redacted] RUTHAIRAT ព្រមទាំងក្មួយទៅលេងប្រទេសជប៉ុន ហើយថ្លៃសំបុត្រយន្តហោះ និងថ្លៃស្នាក់នៅ និងអាហារ គឺឈ្មោះ ក្វាង ជាអ្នកចំណាយ បន្ទាប់មកខ្លួននិងប្អូនថ្លៃព្រមទាំងក្មួយក៏បានធ្វើដំណើរពីប្រទេសថៃ ដោយជិះយន្តឈ្នួលពុំបានយករបស់អ្វីទៅជាមួយទេ ហើយបានស្នាក់នៅទីនោះរយៈពេល០៣ថ្ងៃ ទើបត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលស្នាក់នៅប្រទេសជប៉ុននោះ គឺឈ្មោះ ក្វាង បានទូរស័ព្ទមកពីប្រទេសកម្ពុជា ដែលមានតែ លេខ +៨៥៥ មកខ្លួនប្រាប់ថាមានការងារឱ្យខ្លួន និងប្អូនថ្លៃធ្វើ ដោយការងារនោះគឺ ឱ្យពួកខ្លួនយកថ្នាំប្រភេទជំនួយផ្លូវភេទ ពីខេត្តសៀមរាបប្រទេសកម្ពុជា ទៅប្រទេសជប៉ុន ដោយឱ្យតម្លៃឈ្នួលក្នុងម្នាក់ចំនួន ៣០០០ ដុល្លារអាមេរិក ពេលធ្វើការបានរួចរាល់បន្ទាប់ពីនិយាយគ្នា ចប់ខ្លួន និងប្អូនថ្លៃ ព្រមទាំងក្មួយធ្វើដំណើរពីប្រទេសថៃ ដោយជិះរថយន្តតាក់ស៊ី និងបានមកដល់ជាយដែនខ្មែរ-ថៃ នៅវេលាម៉ោងប្រមាណដប់យប់ រួចក៏បានស្នាក់នៅជាយដែនថៃចំនួន០១យប់ លុះព្រឹកឡើងថ្ងៃទី០២ ខែឆ្នាំដដែល វេលាម៉ោងដប់មួយថ្ងៃត្រង់ ក៏បានឆ្លងដែនចូលមកប៉ោយប៉ែត ហើយពេលនោះក៏មានរថយន្តតាក់ស៊ីមកទទួលខ្លួន គាត់បានហុចស៊ីមកាតខ្មែរ ដែលមានលេខ ០៩៦ ៤៩១ ៦៧១៥ ហើយភ្លាមនោះឈ្មោះ ក្វាង បានទូរស័ព្ទមកអ្នកបើកតាក់ស៊ី ហើយសុំនិយាយជាមួយខ្លួន បន្ទាប់ពីបានទទួលស៊ីមកាតហើយខ្លួនក៏បានដាក់ចូលទៅក្នុងទូរស័ព្ទដើម្បីប្រើប្រាស់ទំនាក់ទំនង និងឈ្មោះ ក្វាង ហើយក្នុងអំឡុងពេលដែលកំពុងធ្វើដំណើរតាមផ្លូវពីប៉ោយប៉ែតទៅសៀមរាបឈ្មោះ ក្វាង តែងតែទូរស័ព្ទនិយាយមកខ្លួន លុះដល់វេលាម៉ោងដប់បួន ពួកខ្លួនបានធ្វើដំណើរទៅដល់ខេត្តសៀមរាប ហើយបានទៅញ៉ាំបាយនៅក្បែរសណ្ឋាគារ ដោយខ្លួនជាមួយឈ្មោះ ក្វាង និងសង្សាររបស់គាត់ រហូតដល់វេលាម៉ោង១១ និង៣០នាទី ក៏បានញ៉ាំបាយរួចរាល់ ពេលនោះឈ្មោះ ក្វាង ក៏បាននិយាយណាត់ជួបខ្លួន នៅវេលាម៉ោងដប់ពីរ ដើម្បីប្រគល់ទទួលថ្នាំរបស់ដែលត្រូវផ្ញើរទៅជប៉ុន នៅចំណុចផ្លូវលំ ក្បែរហាងកាហ្វេ ដែលស្ថិតនៅមិនឆ្ងាយពីសណ្ឋាគារដែលខ្លួនស្នាក់នៅឡើយ លុះដល់ម៉ោងណាត់ខ្លួនក៏បានទៅជួបឈ្មោះ ក្វាង តាមការណាត់ ជួបពេលទៅដល់ខ្លួនក៏បានជួបឈ្មោះ ក្វាង តាមការណាត់ជួប ខ្លួនបានជួបឈ្មោះ ក្វាង និងបុរសម្នាក់ទៀត ជាជនបរទេស និយាយភាសាអង់គ្លេស ពេលនោះឈ្មោះ ក្វាង បានយកវ៉ាលីរវ៉ាចំនួន០៣ ដែលមានពណ៌ខ្មៅ ចំនួន០២ និងពណ៌ប្រផេះចំនួន០១ ហើយមានថ្នាំសម្រើប ដែលលាក់ទុកបង្កប់នៅខាងក្នុង បន្ទាប់ពីទទួលយករួចហើយឈ្មោះ ក្វាង បាននិយាយថាចាំគាត់ទូរស័ព្ទទៅសួរសុខទុក ខណៈពេលដែលខ្លួនទៅដល់ប្រទេសជប៉ុន ហើយព្រមទាំងបានប្រាប់ និងកត់លេខទូរស័ព្ទសណ្ឋាគារនៅប្រទេសជប៉ុនមកឱ្យខ្លួន ដើម្បីឱ្យខ្លួនងាយស្រួលទាក់ទងទៅស្នាក់នៅ ហើយព្រមទាំងបញ្ជាក់ប្រាប់ខ្លួនថា ពេលខ្លួនយកថ្នាំទៅដល់សណ្ឋាគារនោះនឹងមានបុរសម្នាក់ជនជាតិស្បែកខ្មៅរង់ចាំទទួល។ ក្រោយពីបានស្តាប់ការណែនាំរបស់ឈ្មោះ ក្វាង ចប់សព្វគ្រប់ ខ្លួនក៏បានយកវ៉ាលីទាំងបីខាងលើ មកសណ្ឋាគារដើម្បីរៀបចំដាក់ចូលទៅក្នុងកាបូបយួរដៃរបស់ខ្លួនចំនួន០១ និងបានដាក់ចូលទៅក្នុងកាបូបយួរដៃរបស់



Scanned with CamScanner

ប្អូនថ្លៃខ្លួនចំនួន០២។ លុះដល់វេលាម៉ោងដប់បួន ពួកខ្លួនក៏បានចាកចេញពីសណ្ឋាគារ ឡើងជិះរថយន្តតាក់ស៊ី ដែលឈ្មោះ ក្វាង ជាអ្នករៀបចំធ្វើដំណើរឆ្ពោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហើយបានមកដល់ព្រលានយន្តហោះ នៅវេលាម៉ោងដប់ប្រាំបួន រួចក៏បានត្រួតពិនិត្យចូល (CHECK IN) ហើយក៏បន្តទៅត្រួតពិនិត្យវ៉ាលី និងកាបូបយួរដៃខាងលើបន្ថែមទៀត។ ដោយសមត្ថកិច្ចមានការសង្ស័យទៅលើកាបូបយួរដៃរបស់ខ្លួន និងប្អូនស្រីថានៅក្នុងអាវរងារ ក៏បានធ្វើការហែកត្រួតពិនិត្យបានរកឃើញក្រាម ពណ៌ស ជាច្រើនថង់លាក់បង្កប់ក្នុងអាវទាំងបី បន្ទាប់មកសមត្ថកិច្ចក៏បានយកក្រាមនោះមកធ្វើតេស្តិ៍នៅចំពោះមុខខ្លួន បង្ហាញថាវាជាគ្រឿងញៀន ប្រភេទមេតំហ្វេតាមីន (ICE) រួចក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ឈ្មោះ ក្វាង ជនជាតិថៃ អាយុប្រហែល៣៥ឆ្នាំ កម្ពស់ប្រហែល១,៥៥ម៉ែត្រ រាងធាត់ សម្បុរស សក់ទង់ដែង លេខទូរស័ព្ទប្រើប្រាស់ [redacted] ពុំស្គាល់អាសយដ្ឋានស្នាក់នៅ (ពុំទាន់ឃាត់ខ្លួន) និងបុរសមិនស្គាល់ឈ្មោះ ជនជាតិបរទេស អាយុប្រហែល៤៥ឆ្នាំ កម្ពស់ប្រហែក១,៧៥ ម៉ែត្រ រាងស្គម សម្បុរស សក់ពណ៌ស ពុំស្គាល់អាសយដ្ឋានស្នាក់នៅ។ ខ្លួនមិនដឹងថានៅក្នុងអាវរងាមានគ្រឿងញៀននោះទេ ដោយឈ្មោះ ក្វាង បានប្រាប់ថាគ្រាន់តែជាថ្នាំសម្រើបសម្រាប់ផ្លូវភេទប៉ុណ្ណោះ ហើយខ្លួនក៏ជឿជាក់ឈ្មោះ ក្វាង ដោយហេតុថាជាអ្នកស្គាល់យូរ ណាមួយខ្លួនមិនដឹងថាឈ្មោះ ក្វាង ជាអ្នករកស៊ីអញ្ចឹងទេ។ ខ្លួនទើបតែដឹងថាជាគ្រឿងញៀន នៅក្រោយពេលសមត្ថកិច្ចចាប់បានប៉ុណ្ណោះ។

-ចម្លើយជនត្រូវចោទឈ្មោះ [redacted] RUTHAIRAT បានឆ្លើយនាពេលសវនាការថា៖ នៅខែកញ្ញា ឆ្នាំ២០១៧ បងថ្លៃរបស់ខ្លួនឈ្មោះ [redacted] WORAPHA បានបបួលខ្លួននិងកូន ទៅលេងប្រទេសជប៉ុន បងថ្លៃប្រាប់ថា ឈ្មោះ ក្វាង ភេទស្រី ជនជាតិថៃ ជាអ្នកចេញថ្លៃសំបុត្រយន្តហោះ និងការចំណាយផ្សេងៗទៀតទាំងអស់ ក្រោយពីនិយាយរួចហើយ នៅក្នុងខែកញ្ញា ឆ្នាំ២០១៧ ពុំចាំថ្ងៃ ពួកខ្លួនទាំងបី បានចេញពីប្រទេសថៃ ទៅជួបឈ្មោះ ក្វាង ហើយបាននិយាយគ្នារឿងទៅដើរលេងនៅប្រទេសជប៉ុន ពេលទៅដល់ប្រទេសជប៉ុនគ្មាននរណាទៅទទួលទេ គឺពួកខ្លួនជិះរថយន្តបីស ទៅស្នាក់នៅសណ្ឋាគារមិនចាំឈ្មោះ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន បានស្នាក់នៅទីនោះរយៈពេលបីថ្ងៃ ចំពោះលុយត្រូវឈ្មោះ ក្វាង ប្រគល់ឱ្យបងថ្លៃខ្លួនជាអ្នកកាន់។ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ ខ្លួនទាំងបីនាក់បានជិះយន្តហោះមកពីប្រទេសជប៉ុនមកចុះចតនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញប្រទេសកម្ពុជា រួចចេញពីប្រទេសកម្ពុជាទៅព្រលានយន្តហោះដងមឿង ទីក្រុងបាំងកកប្រទេសថៃ។ នៅអំឡុងពេល ខែឧសភា ឆ្នាំ២០១៨ បងថ្លៃរបស់ខ្លួនឈ្មោះ [redacted] WORAPHA បានបបួលខ្លួនទៅលេងប្រទេសជប៉ុនជាលើកទី០២ គាត់បានប្រាប់ខ្លួនថាឈ្មោះ ក្វាង ជាអ្នកចេញលុយឱ្យទាំងអស់។ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៨ ខ្លួននិងបងថ្លៃបានមកប៉ោយប៉ែត ប្រទេសកម្ពុជា ដោយម្តាយចិញ្ចឹមកូនរបស់ខ្លួន បើករថយន្តជូនខ្លួនទាំងបីនាក់មកលេងកាស៊ីណូប៉ោយប៉ែត ពេលមកដល់ព្រំដែន ពួកខ្លួនស្នាក់នៅស្រុកអារញ្ញប្រទេសថៃ មួយយប់ព្រឹកឡើងនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៨ពួកខ្លួនចេញពីស្រុកអារញ្ញ មកប៉ោយប៉ែត ប្រទេសកម្ពុជា ឈ្មោះ ក្វាង បានរៀបចំឱ្យរថយន្តតាក់ស៊ី មកទទួលពួកខ្លួនចេញពីប៉ោយប៉ែត ទៅដល់សៀមរាប។ ពេលទៅដល់សៀមរាបពួកខ្លួនបាន ទៅស្នាក់នៅសណ្ឋាគារតាន់កងអង្គរ ដោយឈ្មោះ ក្វាង បានកក់បន្ទប់ទុកឱ្យជាស្រេច ហើយឈ្មោះ ក្វាង បាននាំពួកខ្លួនទៅញ៉ាំភីសានៅហាងមួយមិនចាំឈ្មោះ និងបានជជែកគ្នាពីរឿងដើរលេង នៅប្រទេសជប៉ុន ក្រោយពីហូបរួចពួកខ្លួនបានមកស្នាក់នៅសណ្ឋាគារ។ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ ពេលថ្ងៃត្រង់ម៉ោងប្រហែល១២ និង០០នាទី បងថ្លៃខ្លួនបានប្រាប់ខ្លួនថា គាត់ចេញទៅក្រៅជួបឈ្មោះ ក្វាង បន្តិចចំណែកខ្លួន និងកូនស្នាក់នៅសណ្ឋាគារដដែល លុះបន្តិចក្រោយមកបងថ្លៃខ្លួនត្រលប់មកវិញ ខ្លួនឃើញបងថ្លៃខ្លួនមានយួរ

កាបូបចំនួនពីរ និងអាវរងារចំនួន០៣ ហើយគាត់បានប្រាប់ថាឈ្មោះ ក្វាង ជាអ្នកឱ្យអាវ និងកាបូបខាងលើ ហើយពួកខ្លួនបានរៀបចំឥវ៉ាន់ចេញពីសណ្ឋាគារ។ នៅវេលាម៉ោង០២ និង៣០នាទី ដោយជិះតាក់ស៊ី ពីសៀមរាបមកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដើម្បីឡើងយន្តហោះពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ សំដៅទៅប្រទេសជប៉ុន។ លុះពេលមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ពេលចូលដល់កន្លែងឆ្លងកាត់ គឺកន្លែងត្រួតពិនិត្យក៏សមត្ថកិច្ចសង្ស័យក៏ធ្វើការត្រួតពិនិត្យជាក់ស្តែងរកឃើញមានគ្រឿងញៀន ដែលលាក់បង្កប់នៅក្នុងអាវរងារទាំងបីខាងលើ ក៏ធ្វើការឃាត់ខ្លួនជាក់ស្តែង និងចាប់យកវត្ថុតាងគ្រឿងញៀនតែម្តង។ ខ្លួនមិនបានដឹងថាអាវរងារនោះមានលាក់បង្កប់ថ្នាំញៀននោះទេ ពីព្រោះបងថ្លៃខ្លួនបានប្រាប់ថា ឈ្មោះ ក្វាង បានប្រាប់ថា ក្នុងអាវរងារនោះមានលាក់បង្កប់ថ្នាំកម្លាំង គឺសម្រាប់ជំនួយផ្លូវភេទ។

-ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] បានឆ្លើយនាពេលសវនាការថា៖ ខ្លួនពិតជាបានចូលរួមប្រតិបត្តិបង្ក្រាបគ្រឿងញៀននេះពិតប្រាកដមែន។ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ សមត្ថកិច្ចបានសង្ស័យទៅលើអាវរងាររបស់ជនជាប់ចោទទាំងខាងលើ ដែលអាវរងារនោះមានចំនួន០៣ ហើយខាងស្កាប់ប័ត្របានរាយការណ៍មកខ្លួន ហើយខ្លួនក៏បានរាយការណ៍ទៅព្រះរាជអាជ្ញា [redacted] និងបានឆែកឆេររកឃើញសារធាតុញៀន។ អាវទាំងនោះ គឺជនជាប់ចោទឈ្មោះ TONGOON WORAPHA កាន់នៅនឹងដៃចំនួន០១ និងឈ្មោះ [redacted] RUTHAIRAT កាន់នៅនឹងដៃចំនួន០២។ ក្រោយឆែកឆេរ ឃើញថាថ្នាំញៀនទាំងនោះបានច្រកជាកញ្ចប់តូចៗជាច្រើន ហើយដេរជិតនៅក្នុងអាវរងារ។ គ្រឿងញៀនជាប្រភេទម្សៅក្រាមពណ៌ស ដោយបានធ្វើតេស្តបឋមឃើញថា ជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ដែលមានទម្ងន់សរុប ១១៥០,៧០ក្រាម។ ខ្លួនសូមបញ្ជាក់ថា ការប្រតិបត្តិការឆែកឆេរនៅពេលនោះ គឺប្រព្រឹត្តទៅនៅចំពោះមុខជនជាប់ចោទ ហើយជនជាប់ចោទក៏បានទទួលថាអាវនោះជារបស់គាត់ដែលបានមកពីជនម្នាក់ឱ្យគាត់យកទៅជប៉ុន ដោយប្រាប់ថាជាថ្នាំជំនួសផ្លូវភេទ។

-ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] បានឆ្លើយនាពេលសវនាការថា៖ ខ្លួនបានចូលរួមក្នុងប្រតិបត្តិការបង្ក្រាបគ្រឿងញៀនខាងលើផងដែរ តែសហការីរបស់ខ្លួនជាអ្នកពិនិត្យឃើញ។ សហការីរបស់ខ្ញុំបានពិនិត្យឃើញនៅម៉ោង០៨យប់ ថ្ងៃកើតហេតុ ដោយពិនិត្យលើអាវរងារតាមរយៈ X-ray ឃើញថាមានលក្ខណៈសង្ស័យថាជាសារធាតុញៀន។ ចំនួនអាវគឺមានបី តែខ្លួនមិនបានដឹងទេថាជនជាប់ចោទទាំងពីរបានកាន់ម្នាក់ប៉ុន្មាននោះទេ។ នៅក្នុងនោះអាវដែរឈ្មោះ [redacted] WORAPHA កាន់មានគ្រឿងញៀនទម្ងន់១៧៥០,៧៦ក្រាម និងរបស់ឈ្មោះ [redacted] RUTHAIRAT មានទម្ងន់ ២៧៥៦,៤៤ក្រាម ជាប្រភេទមេតំហ្វេតាមីន ដេរផ្ចិតបង្កប់នៅក្នុងអាវរងារ។ អាវនោះដាក់នៅក្នុងកាបូបយួរដៃ។ ថ្នាំញៀននេះ ជនជាប់ចោទទាំងពីរមានគម្រោងដឹកទៅប្រទេសជប៉ុន តាមជើងហោះហើរលេខ N១៧៨១៨ ពីទីក្រុងភ្នំពេញ ទៅទីក្រុងណារីតា ប្រទេសជប៉ុន។

## សេចក្តីសន្និដ្ឋានម្តងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា: ក្រោយពីបានស្តាប់ចម្លើយនៅក្នុងសវនាការ លើសំណុំរឿងមក ឃើញថាជនជាប់ចោទឈ្មោះ [redacted] WORAPHA បានទទួលថាខ្លួនបានធ្វើបានជិះជើងហោះហើរពីកម្ពុជា ទៅប្រទេសជប៉ុន ពិតមែន និងបានកាន់អាវរងារដែលមានបង្កប់ថ្នាំ ដែលឈ្មោះ ក្វាង ប្រាប់ថាជាប្រភេទថ្នាំជំនួយផ្លូវភេទ ដែលចម្លើយនេះគ្រាន់តែជាចម្លើយឆ្លើយដោះសារយករួចខ្លួន ដោយហេតុថាជនជាប់ចោទបានដឹងថាថ្នាំនោះជាអ្វី និងបាន



Scanned with CamScanner

ទទួលកម្រៃដឹកជញ្ជូនផងដែរ និងក្រោយពីសមត្ថកិច្ចឃាត់ខ្លួន និងពិនិត្យឃើញថានៅក្នុងកាវទាំងនោះជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន។ ប្រសិនមកគាត់មិនបានដឹង ហេតុអ្វីគាត់នៅតែទទួលយកទៅប្រទេសជប៉ុនតាមការឧបត្ថម្ភរបស់ឈ្មោះ ក្វាង។ ចំណែកចម្លើយរបស់ឈ្មោះ[redacted]RUTHAIRAT ក៏ដូចគ្នាផងដែរ ដោយព្រមទទួលព្រមទទួលយកទំនិញដឹកទៅប្រទេសជប៉ុន ដោយទទួលតម្លៃឈ្នួល ៥០០០០បាត ហើយយើងបានសួរថាថ្នាំនោះខុសច្បាប់ដែរឬទេ តែជនជាប់ចោទបាននិយាយថាខ្លួនមិនដឹងទេ។ តាមទំនិញដែលបានដកហូត និងស្ដាប់លទ្ធផលកោសល្យវិច័យ ឃើញថាជាប្រភេទ មេតំហ្វេតាមីន មិនមែនជាថ្នាំជំនួយផ្លូវភេទ ដូចការបកស្រាយរបស់ជនជាប់ចោទនោះទេ។ ឃើញថា ជនជាប់ចោទជានីតិជន និងពិតជាមានពិរុទ្ធពិតមែន ដូច្នេះតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរនៅដដែល និងស្នើសុំតុលាការផ្ដន្ទាទោសតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-លោកមេធាវី[redacted]ហ្វុនឡាយ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]WORAPHA, និង ឈ្មោះ[redacted]RUTHAIRAT បានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីការសួរដេញដោល និងពិនិត្យឯកសារនៅក្នុងសំណុំរឿង សង្កេតឃើញថា កូនក្ដីរបស់ខ្លួនបានចាញ់បោកឈ្មោះ ក្វាង ដោយគាត់មានបំណងទៅប្រទេសជប៉ុន ហើយឈ្មោះ ក្វាង បានផ្ញើរកាវងារចំនួន០៣ និងកូនក្ដីខ្លួនមិនបានបើកមើលទេ ហើយសមត្ថកិច្ចក៏បានបញ្ជាក់ផងដែរថា កូនក្ដីរបស់ខ្លួនមិនបានបើកមើលកាវនោះដែរ។ម្យ៉ាងទៀតរបស់គេដែលអ្នកដទៃផ្ញើរ យើងមិនគួរគប្បីបើកមើលទេ ព្រោះវាធ្វើឱ្យបាត់បង់ទំនាក់ទំនង។ មួយទៀតមានតែឈ្មោះ ក្វាង ទេដែលអាចបញ្ជាក់ថាកូនក្ដីរបស់ខ្លួន ដឹងឬមិនដឹង តែគាត់រត់បាត់ហើយ ដូច្នេះសំដីរបស់កូនក្ដីរបស់ខ្ញុំជាពាក្យពិត។ កូនក្ដីរបស់ខ្លួនមិនមានចេតនាប្រព្រឹត្ត ដូច្នេះមិនគ្រប់គ្រាន់នៃធាតុផ្សំនៃបទល្មើស ដែលផ្ទុយពីមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ។ របាយការណ៍មន្ត្រីគ្រឿងញៀនឃើញថា គ្រឿងញៀន១៧៥០,៧០ក្រាម ជារបស់ឈ្មោះ[redacted]WORAPHA និងគ្រឿងញៀនទម្ងន់ ២៧០៥០,៤៤ក្រាម ជារបស់ឈ្មោះ[redacted]RUTHAIRAT ចំណែកទិន្នន័យអយ្យការវិញឃើញថាឃើញថាវាផ្ទុយគ្នា ដោយបរិមាណផ្ទុយ ដូច្នេះស្នើសុំតុលាការសម្រេចឱ្យកូនក្ដីរបស់ខ្លួនរួចផុតពីបទចោទ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-លោកមេធាវី[redacted]ណូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]KANOKNUD ហៅ ភ្នាខ បានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីសួរនៅក្នុងសវនាការរួចមក ឃើញថាជនជាប់ចោទទាំងពីរបានឆ្លើយដាក់បន្ទុកទៅលើកូនក្ដីខ្លួន តែគាត់មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលបង្ហាញថាកូនក្ដីរបស់ខ្លួន ពិតជាបានប្រព្រឹត្តមែននោះទេ ដោយនេះជាវិមតិសង្ស័យ ដែលស្របតាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះស្នើសុំតុលាការសម្រេចលើកលែងការចោទប្រកាន់ដល់កូនក្ដីរបស់ខ្លួន។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ[redacted]WORAPHA និងឈ្មោះ[redacted]RUTHAIRAT សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើខ្លួន ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

-កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ នៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ពិតជាមានអំពើ រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កើតឡើងពិតមែន។

-តាមចម្លើយជនជាប់ចោទ [redacted] WORAPHA បានឆ្លើយថា៖ ខ្លួនពិតជាបានជួយ ដឹកជញ្ជូន ថ្នាំពីប្រទេសកម្ពុជា ទៅទីក្រុងតូក្យូ ប្រទេសជប៉ុន ឱ្យឈ្មោះ ក្វាង ពិតប្រាកដមែន ដោយបង្កប់នៅក្នុងអាវរងាចំនួនបី ដែលខ្លួនដាក់ចូលទៅក្នុងកាបូបយួរដៃរបស់ខ្លួនចំនួន០១ និងបានដាក់ចូលទៅក្នុងកាបូបយួរដៃរបស់ប្អូនថ្លៃខ្លួនចំនួន០២ តែខ្លួនមិនដឹងថាវាគឺជាថ្នាំញៀននោះទេ ដោយហេតុថាឈ្មោះ ក្វាង បានប្រាប់ថាវាជាថ្នាំជំនួយផ្លូវភេទប៉ុណ្ណោះ។ លុះដល់វេលាម៉ោងដប់បួន ពួកខ្លួនក៏បានចាកចេញពីសណ្ឋាគារ ឡើងជិះរថយន្តតាក់ស៊ី ដែលឈ្មោះ ក្វាង ជាអ្នករៀបចំធ្វើដំណើរឆ្ពោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហើយបានមកដល់ព្រលានយន្តហោះ នៅវេលាម៉ោងដប់ប្រាំបួន រួចក៏បានត្រួតពិនិត្យចូល (CHECK IN) ហើយក៏បន្តទៅត្រួតពិនិត្យវ៉ាលី និងកាបូបយួរដៃខាងលើបន្ថែមទៀត។ ដោយសមត្ថកិច្ចមានការសង្ស័យទៅលើកាបូបយួរដៃរបស់ខ្លួន និងប្អូនស្រីថានៅក្នុងអាវរងារមានលាក់បង្កប់គ្រឿងញៀន ក៏បានធ្វើការហែកត្រួតពិនិត្យបានរកឃើញក្រាមពណ៌ស ជាច្រើនផងលាក់បង្កប់ក្នុងអាវទាំងបី បន្ទាប់មកសមត្ថកិច្ចក៏បានយកក្រាមនោះមកធ្វើតេស្តនៅចំពោះមុខខ្លួនបង្ហាញថាវាជាគ្រឿងញៀន ប្រភេទមេតំហ្វេតាមីន (ICE) រួចក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនដឹងថានៅក្នុងអាវរងាមានគ្រឿងញៀននោះទេ ដោយឈ្មោះ ក្វាង បានប្រាប់ថាគ្រាន់តែជាថ្នាំសម្រើបសម្រាប់ផ្លូវភេទប៉ុណ្ណោះ ហើយខ្លួនក៏ជឿជាក់ឈ្មោះ ក្វាង ដោយហេតុថាជាអ្នកស្គាល់យូរ ណាមួយខ្លួនមិនដឹងថាឈ្មោះ ក្វាង ជាអ្នករកស៊ីអញ្ជើងទេ។ ខ្លួនទើបតែដឹងថាជាគ្រឿងញៀន នៅក្រោយពេលសមត្ថកិច្ចចាប់បានប៉ុណ្ណោះ ចម្លើយនេះគ្រាន់តែជាការឆ្លើយដោះសារយករួចខ្លួនប៉ុណ្ណោះដោយគ្មានភស្តុតាង និងសាក្សីបញ្ជាក់ អាចឱ្យតុលាការជឿជាក់ទេ។

-តាមចម្លើយជនត្រូវចោទឈ្មោះ [redacted] RUTHAIRAT បានឆ្លើយថា៖ នៅអំឡុងពេល ខែឧសភា ឆ្នាំ២០១៨ បងថ្លៃរបស់ខ្លួនឈ្មោះ [redacted] WORAPHA បានបបួលខ្លួនទៅលេងប្រទេសជប៉ុន គាត់បានប្រាប់ខ្លួនថាឈ្មោះ ក្វាង ជាអ្នកចេញលុយឱ្យទាំងអស់។ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៨ ខ្លួននិងបងថ្លៃបានមកប៉ោយប៉ែត ប្រទេសកម្ពុជា ដោយម្តាយចិញ្ចឹមកូនរបស់ខ្លួន បើករថយន្តជូនខ្លួនទាំងបីនាក់មកលេងកាស៊ីណូប៉ោយប៉ែត ពេលមកដល់ព្រំដែន ពួកខ្លួនស្នាក់នៅស្រុកអរញ្ញប្រទេសថៃ មួយយប់ព្រឹកឡើងនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៨ ពួកខ្លួនចេញពីស្រុកអរញ្ញ មកប៉ោយប៉ែត ប្រទេសកម្ពុជា ឈ្មោះ ក្វាង បានរៀបចំឱ្យរថយន្តតាក់ស៊ី មកទទួលពួកខ្លួនចេញពីប៉ោយប៉ែត ទៅដល់សៀមរាប។ ពេលទៅដល់សៀមរាបពួកខ្លួនបាន ទៅស្នាក់នៅសណ្ឋាគារតាន់កងអង្គរ ដោយឈ្មោះ ក្វាង បានកក់បន្ទប់ទុកឱ្យជាស្រេច ហើយឈ្មោះ ក្វាង បាននាំពួកខ្លួនទៅញ៉ាំភីសានៅហាងមួយមិនចាំឈ្មោះ និងបាននជជែកគ្នាពីរឿងដើរលេង នៅប្រទេសជប៉ុន ក្រោយពី



Scanned with CamScanner

ហ្វូបរួចពួកខ្លួនបានមកស្នាក់នៅសណ្ឋាគារ។ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ ពេលថ្ងៃត្រង់ម៉ោងប្រហែល១២ និង០០នាទី បងថ្លៃខ្លួនបានប្រាប់ខ្លួនថា គាត់ចេញទៅក្រៅជួបឈ្មោះ ក្វាង បន្តិច ចំណែកខ្លួន និងកូនស្នាក់នៅសណ្ឋាគារដដែល លុះបន្តិចក្រោយមកបងថ្លៃខ្លួនត្រលប់មកវិញ ខ្លួនឃើញបងថ្លៃខ្លួនមានយួរកាបូបចំនួនពីរ និងអាវរងារចំនួន០៣ ហើយគាត់បានប្រាប់ថាឈ្មោះ ក្វាង ជាអ្នកឱ្យអាវ និងកាបូបខាងលើ ហើយពួកខ្លួនបានរៀបចំឥវ៉ាន់ចេញពីសណ្ឋាគារ។ នៅវេលាម៉ោង០២ និង៣០នាទី ដោយជិះតាក់ស៊ី ពីសៀមរាបមកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដើម្បីឡើងយន្តហោះពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ សំដៅទៅប្រទេសជប៉ុន។ លុះពេលមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ពេលចូលដល់កន្លែងឆ្លងកាត់ គឺកន្លែងត្រួតពិនិត្យក៏សមត្ថកិច្ចសង្ស័យក៏ធ្វើការត្រួតពិនិត្យជាក់ស្តែងរកឃើញមានគ្រឿងញៀន ដែលលាក់បង្កប់នៅក្នុងអាវរងារទាំងបីខាងលើ ក៏ធ្វើការឃាត់ខ្លួនជាក់ស្តែង និងចាប់យកវត្ថុតាងគ្រឿងញៀនតែម្តង។ ខ្លួនមិនបានដឹងថាអាវរងារនោះមានលាក់បង្កប់ថ្នាំញៀននោះទេ ពីព្រោះបងថ្លៃខ្លួនបានប្រាប់ថា ឈ្មោះ ក្វាង បានប្រាប់ថា ក្នុងអាវរងារនោះមានលាក់បង្កប់ថ្នាំកម្លាំង គឺសម្រាប់ជំនួយផ្លូវភេទ ចម្លើយនេះគ្រាន់តែជាការឆ្លើយដោះសារយករួចខ្លួនប៉ុណ្ណោះ ដោយគ្មានភស្តុតាង និងសាក្សីបញ្ជាក់ អាចឱ្យតុលាការជឿជាក់ទេ។

-តាមចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនពិតជាបានចូលរួមប្រតិបត្តិបង្ក្រាបគ្រឿងញៀននេះពិតប្រាកដមែន។ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ សមត្ថកិច្ចបានសង្ស័យទៅលើអាវរងាររបស់ជនជាប់ចោទទាំងខាងលើ ដែលអាវរងារនោះមានចំនួន០៣ ហើយខាងស្ថាប័នគយបានរាយការណ៍មកខ្លួន ហើយខ្លួនក៏បានរាយការណ៍ទៅព្រះរាជអាជ្ញា [redacted] និងបានឆែកឆេររកឃើញសារធាតុញៀន។ អាវទាំងនោះ គឺជនជាប់ចោទឈ្មោះ [redacted] WORAPHA កាន់នៅនឹងដៃចំនួន០១ និងឈ្មោះ [redacted] RUTHAIRAT កាន់នៅនឹងដៃចំនួន០២។ ក្រោយឆែកឆេរ ឃើញថាថ្នាំញៀនទាំងនោះបានច្រកជាកញ្ចប់តូចៗជាច្រើន ហើយដេរជិតនៅក្នុងអាវរងារ។ គ្រឿងញៀនជាប្រភេទម្សៅក្រាមពណ៌ស ដោយបានធ្វើតេស្តបឋមឃើញថា ជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ដែលមានទម្ងន់សរុប១១៥០,៧០ក្រាម។ ខ្លួនសូមបញ្ជាក់ថា ការប្រតិបត្តិការឆែកឆេរនៅពេលនោះ គឺប្រព្រឹត្តទៅនៅចំពោះមុខជនជាប់ចោទ ហើយជនជាប់ចោទក៏បានទទួលថាអាវនោះជារបស់គាត់ដែលបានមកពីជនម្នាក់ឱ្យគាត់យកទៅជប៉ុន ដោយប្រាប់ថាជាថ្នាំជំនួសផ្លូវភេទ។

-តាមចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនបានចូលរួមក្នុងប្រតិបត្តិការបង្ក្រាបគ្រឿងញៀនខាងលើផងដែរ តែសហការីរបស់ខ្លួនជាអ្នកពិនិត្យឃើញ។ សហការីរបស់ខ្ញុំបានពិនិត្យឃើញនៅម៉ោង០៨យប់ថ្ងៃកើតហេតុ ដោយពិនិត្យលើអាវរងារតាមរយៈ X-ray ឃើញថាមានលក្ខណៈសង្ស័យថាជាសារធាតុញៀន។ ចំនួនអាវគឺមានបី តែខ្លួនមិនបានដឹងទេថាជនជាប់ចោទទាំងពីរបានកាន់ម្នាក់ប៉ុន្មាននោះទេ។ នៅក្នុងនោះអាវដែរឈ្មោះ [redacted] WORAPHA កាន់មានគ្រឿងញៀនទម្ងន់១៧៥០,៧៦ក្រាម និងរបស់ឈ្មោះ [redacted] RUTHAIRAT មានទម្ងន់២៧៥៦,៤៤ក្រាម ជាប្រភេទមេតំហ្វេតាមីន ដេរផ្អិតបង្កប់នៅក្នុងអាវរងារ។ អាវនោះដាក់នៅក្នុងកាបូបយួរដៃ។ ថ្នាំញៀននេះ ជនជាប់ចោទទាំងពីរមានគម្រោងយឹងទៅប្រទេសជប៉ុន តាមជើងហោះហើរលេខ N១៧៨១៨ ពីទីក្រុងភ្នំពេញ ទៅទីក្រុងណារីតា ប្រទេសជប៉ុន។

-តាមចម្លើយរបស់ជនជាប់ចោទ, មន្ត្រីនគរបាលយុត្តិធម៌ និងរបាយការណ៍របស់សមត្ថកិច្ច ព្រមទាំងវត្ថុតាងដែលចាប់យកជាក់ស្តែង ឃើញថាជនជាប់ចោទឈ្មោះ [redacted] WORAPHA, ឈ្មោះ [redacted] KANOKNUD ហៅ ភ្វាខ

និងឈ្មោះ [redacted] RUTHAIRAT ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក, ដឹកជញ្ជូន, ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន។

-សកម្មភាពរបស់ជនជាប់ចោទ ដែលរក្សាទុក, ដឹកជញ្ជូន និងលក់គ្រឿងញៀន ដោយខុសច្បាប់ ត្រូវបានកំណត់ថា ជាបទល្មើស រក្សាទុក, ដឹកជញ្ជូន, ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅលើមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទជានីតិជន និង ជាជនដែលមានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

-ការលើកឡើងរបស់តំណាងអយ្យការក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការថា តាមអង្គហេតុ និងវត្ថុដែលចាប់យកបញ្ជាក់ថាជនជាប់ចោទពិតបាន រក្សាទុក, ដឹកជញ្ជូន, ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតមែន ហេតុដូចនេះ តំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់លើជនជាប់ចោទដូចក្នុង ដីកាសន្និដ្ឋានស្ថាពរលេខ: ៣៦១២ អ.យ.ឋ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៨ដដែល មានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណា ។

-ការលើកឡើងរបស់មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] WORAPHA និងឈ្មោះ [redacted] RUTHAIRAT បានលើកឡើងថា៖ កូនក្តីរបស់ខ្លួនបានចាញ់បោកឈ្មោះ ក្វាង ដោយគាត់មានបំណង់ទៅប្រទេសជប៉ុន ហើយឈ្មោះ ក្វាង បានផ្ញើរអាវរងារចំនួន០៣ និងកូនក្តីខ្លួនមិនបានបើកមើលទេ ហើយសមត្ថកិច្ចក៏បានបញ្ជាក់ផងដែរថា កូនក្តីរបស់ខ្លួនមិនបានបើកមើលអាវនោះដែរ។ កូនក្តីរបស់ខ្លួនមិនមានចេតនាប្រព្រឹត្ត ដូច្នេះមិនគ្រប់គ្រាន់នៃធាតុផ្សំនៃបទល្មើស ដែលផ្ទុយពីមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ដូច្នេះស្នើសុំតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ ឃើញថាមិនមានភស្តុតាងមកបញ្ជាក់អាចឱ្យតុលាការជឿបានឡើយ។

-ការលើកឡើងរបស់មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] KANOKNUD បានលើកឡើងថា៖ ក្រោយពីសួរនៅក្នុងសវនាការរួចមក ឃើញថាជនជាប់ចោទទាំងពីរបានឆ្លើយដាក់បន្ទុកទៅលើកូនក្តីខ្លួន តែគាត់មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលបង្ហាញថាកូនក្តីរបស់ខ្លួន ពិតជាបានប្រព្រឹត្តមែននោះទេ ដោយនេះជាវិមតិសង្ស័យ ដែលស្រមតាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះស្នើសុំតុលាការសម្រេចលើកលែងការចោទប្រកាន់ដល់កូនក្តីរបស់ខ្លួន ឃើញថាមិនមានភស្តុតាងមកបញ្ជាក់អាចឱ្យតុលាការជឿបានឡើយ។

-តាមលទ្ធផលកោសល្យវិច័យរបស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លេខ១៥១៨៤/១៨ ម.ព.អ.ជ.ប.គ.ញ និងលេខ១៥១៨៣/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ឃើញថា៖ សំណាកជាគ្រឿងញៀនប្រភេទម្សៅ ឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៤៧.៥១% នៃទម្ងន់សរុប, វាស្ថិតនៅក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលំអិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។



Scanned with CamScanner

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ, ឈ្មោះ [redacted] RUTHAIRAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ និងឈ្មោះ [redacted] KANOKNUD ហៅ ក្វាង ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិថៃ ពីបទ: រក្សាទុក, ដឹកជញ្ជូន, ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសជនជាប់ចោទ:

១.១ ឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ (មានសារតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយ:ពេល ៣០ឆ្នាំ (សាមសិបឆ្នាំ) និងពិន័យជាប្រាក់ចំនួន៦០លានរៀល (ហុកសិបលានរៀល)។

១.២ ឈ្មោះ [redacted] RUTHAIRAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ (មានសារតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយ:ពេល ៣០ឆ្នាំ (សាមសិបឆ្នាំ) និងពិន័យជាប្រាក់ចំនួន៦០លានរៀល (ហុកសិបលានរៀល)។

១.៣ ឈ្មោះ [redacted] KANOKNUD ហៅ ក្វាង ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិថៃ (មានសារតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយ:ពេល ៣០ឆ្នាំ (សាមសិបឆ្នាំ) និងពិន័យជាប្រាក់ចំនួន៨០លានរៀល (ប៉ែតសិបលានរៀល)។

ពីបទ: រក្សាទុក, ដឹកជញ្ជូន, ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] KANOKNUD ហៅ ក្វាង ភេទស្រី អាយុ៣៦ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.វត្ថុចាប់យកមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកពីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញលេខ៧៧០ ប.វ.គ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ មាន ៖ ១. ម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ២,៧៥៦.៤៤ (ពីរពាន់ប្រាំពីររយហាសិបក្រាម និងសែសិបបួន), និង ២. ក្រាមពណ៌សថ្លា ទម្ងន់សរុប ១,៧៥០.៧៦ (មួយពាន់ប្រាំពីររយហាសិបក្រាម និងចិតសិបប្រាំមួយ) សម្រេចរឹបអូសតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៨៣ និងមាត្រា៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន , ៣. ទូរស័ព្ទម៉ាក Oppo ពណ៌ស-ផ្កាឈូក មិនដំណើរការ ០១គ្រឿង និងម៉ាក HUAWEI ពណ៌ទឹកមាស មិនដំណើរការ ០១គ្រឿង និងអត្តសញ្ញាណប័ណ្ណជនជាតិថៃ ចំនួន០១សន្លឹក, លិខិតឆ្លងដែន ចំនួន០២ក្បាល និងសំបុត្រយន្តហោះចំនួន០១សន្លឹក សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណ:នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] WORAPHA, និងឈ្មោះ [redacted] RUTHAIRAT និងកំបាំងមុខជនត្រូវចោទឈ្មោះ [redacted] KANOKNUD ហៅ ក្វាង និងប្រកាសជាសាធារណ: នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះមុខ



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] WORAPHA, និងឈ្មោះ [redacted] RUTHAIRAT និងកំបាំងមុខជនត្រូវចោទឈ្មោះ [redacted] KANOKNUD ហៅ **ភ្នាង** ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ៣រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩
**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner